ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៤០ សជណ - ជិក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៧

ជម្រាបជូន
ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

**កម្មវត្ថុ៖** ករណីរបាយការណ៍សង្ខេប និងសំណូមពរសំខាន់បី នៃការប្រជុំក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (ក.ជ.វ.ប.) ស្តីពីការជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

**យោង ៖**- លិខិតលេខ ៩១/១៦ ក.ជ.វ.ប. ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៦ របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ និងជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានឃើញ និងឯកភាពលើរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការប្រជុំស្តីពីការជំរុញការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងអនុញ្ញាតជាគោលការណ៍ជូនក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា លើចំណុចដូចខាងក្រោម៖

-កំណត់យក ១-បច្ចេកវិទ្យាកែច្នៃកសិផល ២-បច្ចេកវិទ្យា Software និង Digital Contents ៣-បច្ចេកវិទ្យាជីវសាស្ត្រ ៤-បច្ចេកវិទ្យាវាយនភ័ណ្ឌ ៥-បច្ចេកវិទ្យាវិស្វកម្មកសិកម្ម និង៦-បច្ចេកវិទ្យារូបធាតុសម្ភារ ជាបច្ចេកវិទ្យាអាទិភាពជាតិសម្រាប់ឆ្នាំ២០១៧-២០២០ ហើយក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាអភិវឌ្ឍជាយុទ្ធសាស្ត្រអាទិភាពជាតិបន្ថែមលើបច្ចេកវិទ្យាជំនាញនៃក្រសួង-ស្ថាប័ននីមួយៗ

-បង្កើនការវិនិយោគរបស់រដ្ឋលើការស្រាវជ្រាវនិងអភិវឌ្ឍ (R&D) ឱ្យបានដល់ ០.១% នៃផ.ស.ស. ត្រឹមឆ្នាំ២០២០ និង ០.៤% នៃផ.ស.ស. ត្រឹមឆ្នាំ២០២៥ ហើយអគ្គលេខាធិការដ្ឋាន ក.ជ.វ.ប. ត្រូវរៀបចំបង្កើតមូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលរដ្ឋនឹងរួមចំណែកថវិកាជាមធ្យម ០.០១៣% នៃផ.ស.ស. ក្នុងមួយឆ្នាំ ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ ហើយនិងកើនដល់ ០.១២% នៃផ.ស.ស. នៅឆ្នាំ២០២៥

-ផ្តល់អាទិភាពសម្រាប់ការទទួលជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដល់កិច្ចការអភិវឌ្ឍ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

អាស្រ័យហេតុនេះ សូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាជ្រាប និងចាត់ចែងតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**កែវ រ៉េមី**

**ចម្លងជូន:**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ